# ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍

## ជំពូក ១: ឧស្សាហកម្មនានសេដ្ឋកិច្ចមួយចំនួនដែលនាំដល់ការធ្វើពាណិជ្ជកម្មសកល

### ១. ហេតុអ្វីការធ្វើពាណិជ្ជកម្មពីប្រទេសមួយទៅប្រទេសមួយកើតឡើង?

យោងតាមទ្រឹស្តីសេដ្ឋកិច្ច ភាពរីកចម្រើនដើរទៅទន្ទឹមគ្នានឹងពាណិជ្ជកម្ម នៅពេលដែលមនុស្សត្រូវការពឹងផ្អែកគ្នាទៅវិញទៅមកដើម្បីភាពរីកចម្រើន ក៏ដូចជាប្រទេសមួយពឹងផ្អែកលើទំនិញ និងសេវាកម្មរបស់ប្រទេសដទៃទៀតដែល ត្រូវការ ហើយគំនិតទាំងនេះនាំឱ្យមានជាការធ្វើពាណិជ្ជកម្មសេរី។ **ពាណិជ្ជកម្មសេរី** មានន័យថាលុបបំបាត់ របាំងពាណិជ្ជកម្មលើទំនិញ និងសេវាកម្មពីប្រទេសមួយទៅប្រទេសមួយ។ យោងតាមសេដ្ឋកិច្ចវិទូ ការធ្វើ ពាណិជ្ជកម្មសេរី គឺមានភាពប្រសើរជាង ដោយសារតម្លៃទំនិញនឹងថោកជាងធម្មតា ហើយជីវភាពប្រជាជនក៏ កាន់តែបានលើកកម្ពស់ នៅពេលរបាំងពាណិជ្ជកម្មត្រូវបានបំបាត់ចោល។

ទោះបីប្រទេសជឿនលឿនដូចជា សហរដ្ឋអាមេរិក ឬជប៉ុន ឬប្រទេសនៅអឺរ៉ុបខាងលិច ក៏ត្រូវការធ្វើពាណិជ្ជកម្មដែរ។ ការធ្វើពាណិជ្ជកម្មកើតឡើងដោយសារគ្មានប្រទេសណាមួយអាចផលិតអ្វីៗបានទាំងអស់ទេ ឬសូម្បីតែអាច ផលិតទៅ រួចក៏នៅតែប្រសើរជាងក្នុងការនាំចូលទំនិញ និងសេវាកម្មដែលប្រទេសដទៃផលិតបានល្អជាង ហើយនាំចេញនូវទំនិញដែលប្រទេសខ្លួនផលិតបានប្រសើរជាង។ ឧទាហរណ៍: សហរដ្ឋអាមេរិក គឺជាប្រទេសឈានមុខគេខាងបច្ចេកវិទ្យា ទំនើប និងមានម៉ាស៊ីនទាន់សម័យដែលអាចផលិតម៉ាស៊ីនដទៃទៀត ប៉ុន្តែសហរដ្ឋអាមេរិកក៏មិនអាចផលិត micro chip របស់កុំព្យូទ័របានក្នុងតម្លៃថោកដូចប្រទេសហ្វីលីពីនដែរ។

តាមទ្រឹស្តី comparative advantage បានបង្ហាញថា ប្រទេសខ្លះអាចផលិតទំនិញ និងសេវាកម្មមួយចំនួនមានប្រសិទ្ធភាពជាងប្រទេសផ្សេងទៀត។ ជាទូទៅ ប្រទេសនានាចង់នាំចេញនូវផលិតផលដែលគេអាចផលិតបានល្អ និងនាំចូលនូវផលិតផលដែលគេពិបាកផលិត។

### ២. តើអ្នកប្រើប្រាស់ និងផលិតករទទួលប្រយោជន៍ពីពាណិជ្ជកម្មយ៉ាងណា?

ប្រសិនបើប្រទេស **ក** ផលិតស្រូវក្នុងតម្លៃ ១000 ដុល្លារ/តោន ហើយប្រទេស **ខ** ផលិតស្រូវក្នុងតម្លៃ ២000 ដុល្លារ/តោន នោះបញ្ជាក់ឱ្យឃើញថា ប្រទេស **ក** មាន comparative advantage លើប្រទេស **ខ** នាំឱ្យតម្លៃស្រូវ របស់ប្រទេស **ក** ទាបជាង ដោយសារគេអាចផលិតស្រូវមានប្រសិទ្ធភាពក្នុងតម្លៃដើមទាប។ ដូច្នេះ គេ អាចលក់ស្រូវក្នុងតម្លៃទាបជាងប្រទេស **ខ** ហើយអតិថិជននឹងមានការពេញចិត្តចំពោះតម្លៃស្រូវថោក។

តម្រូវការស្រូវពីប្រទេស ក នឹងមានច្រើនជាងប្រទេស ខ ព្រោះតម្លៃស្រូវថោកជាង ដែលនឹងបង្កើតការងារជា ច្រើនក្នុងឧស្សាហកម្មស្រូវ និងឧស្សាហកម្មពាក់ព័ន្ធនៅក្នុងប្រទេស ក ដូចជា ធនាគារដែលផ្តល់ទុនដល់ការនាំចេញ នឹងបង្កើនចំនួនបុគ្គលិក ហើយគេនឹងជួលកម្មករនាវាជាច្រើនដើម្បីដឹកជញ្ជូនស្រូវទៅប្រទេស ខ និងកម្មករសម្រាប់ លើកទំនិញទៅកាន់ផែ ព្រមទាំងតំរូវការអ្នកបើកបរទៅដឹកទំនិញដាក់ឱ្យអតិថិជន។

### ៣. តើមានការខាតបង់អ្វីខ្លះពីពាណិជ្ជកម្ម?

ផលិតករក្នុងស្រុកនឹងរងគ្រោះពីគោលនយោបាយបើកចំហរពាណិជ្ជកម្ម ហើយមានករណីជាច្រើនដែលរដ្ឋាភិបាល អនុញ្ញាតិការនាំចូលទំនិញដែលប្រកួតប្រជែងជាមួយផលិតផលក្នុងស្រុក។ ពួកគេបើកឱ្យទំនិញទាំងនេះចូលមកដោយ សេរី ព្រមទាំងកាត់បន្ថយពន្ធគយលើទំនិញទាំងនេះ ធ្វើតម្លៃទំនិញនាំចូលកាន់តែថោក។ ឧទាហរណ៍ អ្នកផលិតស្រូវ នៅប្រទេស ខ នឹងទទួលរងគ្រោះពីស្រូវនាំចូលពីប្រទេស ក និងប្រទេសដទៃទៀត ព្រោះអ្នកបរិភោគនៅក្នុងប្រទេស ខ នឹងទិញស្រូវនាំចូលជាជាងស្រូវដាំក្នុងស្រុក ដែលនាំឱ្យអ្នកផលិតស្រូវក្នុងស្រុកត្រូវ បង្ខំចិត្តលក់ស្រូវក្នុងតម្លៃទាប មិនអាចរួចថ្លៃដើម ដើម្បីប្រកួតប្រជែងជាមួយស្រូវនាំចូល។ ដូច្នេះ កសិករនឹងឈប់ដាំស្រូវទៀត ព្រោះការធ្វើស្រូវនាំ ឱ្យខាតដើម។

### ៤. តើប្រទេសទាំងអស់យល់ព្រមការបើកពាណិជ្ជកម្មសេរីឬ?

ប្រទេសនិមួយៗមានជំហរផ្សេងគ្នាទៅលើការបើកពាណិជ្ជកម្មសេរី អាស្រ័យលើថាឥទ្ធិពលនៃការធ្វើសេរីកម្ម ពាណិជ្ជកម្មក៏រិតណា។ ប្រសិនបើ គោលនយោបាយពាណិជ្ជកម្មនេះផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច និងចំណូលរបស់ ប្រជាជន នោះរដ្ឋាភិបាល និងប្រជាជនរបស់ប្រទេសនិមួយៗនឹងបើកចំហរពាណិជ្ជកម្មកាន់តែទូលាយ។ តែផ្ទុយទៅ វិញ ប្រសិនបើវាប៉ះពាល់ដល់ចំណូល និងក៏រិតជីវភាពរបស់ប្រជាជន នោះរដ្ឋាភិបាល ក៏ដូចជាប្រជាជននឹងបដិសេដ ចំពោះការបើកចំហរទីផ្សារ។

### ៥. តើគោលនយោបាយពាណិជ្ជកម្មអ្វីខ្លះដែលត្រូវលុបចោល ដើម្បីពង្រីកពាណិជ្ជកម្មសេរី?

QUOTA ត្រូវបានគេស្គាល់ថា ជាការដាក់កំហិតលើបរិមាណ ហើយជាទម្រង់មួយនៃរបាំងពាណិជ្ជកម្មដែល មិនទាក់ទងពន្ធគយ។ វាកំណត់នូវបរិមាណទំនិញដែលអាចនាំចូលទៅប្រទេសមួយ។ ឧទាហរណ៍ ប្រទេស ខ ចង់ការពារអ្នកផលិតស្រូវពីការបាត់បង់លំនឹងជីវភាព ដោយសារការប្រកួតប្រជែងមិនស្មើភាពគ្នាជាមួយស្រូវនាំចូលពី ប្រទេស ក នោះរដ្ឋាភិបាលនៃប្រទេស ខ អាចដាក់ quota ដើម្បីកំណត់បរិមាណស្រូវនាំចូលពីប្រទេស ក។

Quota ធ្វើឡើង ដើម្បីការពារឧស្សាហកម្មមួយពីការប្រកួតប្រជែងរបស់ទំនិញនាំចូល ហើយវាដូចគ្នាទៅការដាក់ ពន្ធគយដែរ។ នៅក្នុងក្របខ័ណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក ការកំណត់Quota ត្រូវជំនួសដោយការដាក់ពន្ធ គយដែលនឹងត្រូវបានគេកាត់បន្ថយ។

ជាមួយគ្នានោះ ពន្ធគយគឺជាពន្ធដែលគេហូតពីទំនិញនាំចូល ដូច្នេះ វាដូចទៅនឹងពន្ធផ្សេងទៀតដែលឆ្លងទៅដល់ អ្នកប្រើប្រាស់ ហើយពន្ធគយធ្វើឱ្យតម្លៃទំនិញនាំចូលកើនឡើង អញ្ចឹងគេត្រូវកាត់បន្ថយពន្ធគយ ដើម្បីធ្វើ ពាណិជ្ជកម្មសេរី។

## ៦. តើប្រទេសនិមួយៗចរចារពាណិជ្ជកម្មរវាងគ្នាយ៉ាងដូចម្តេច?

ក្នុងពេលបច្ចុប្បន្ននេះ ការចរចារច្បាប់ពាណិជ្ជកម្មរបស់ប្រទេសនានាធ្វើឡើងដោយទ្វេភាគី ថ្នាក់តំបន់ និងពហុភាគី ដែលការចរចារទ្វេភាគី គឺជាដំណើរការចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសពីរ ។ ចំណែកឯ កិច្ចព្រមព្រៀង ពាណិជ្ជកម្មថ្នាក់តំបន់ ធ្វើឡើងរវាងប្រទេសមួយក្រុមដែលចងភ្ជាប់គ្នាទៅតាមលក្ខណៈដូចគ្នាមួយចំនួនដូចជា លក្ខណៈ ភូមិសាស្ត្រ ភាសា ប្រវត្តិសាស្ត្ររួមគ្នាជាដើម ។ កិច្ចព្រមព្រៀងនេះនឹងជម្រុញនូវពាណិជ្ជកម្មកាន់តែធំឡើង និងភាពរីកចម្រើនជាមួយគ្នាក្នុងចំណោមប្រទេសជាសមាជិក ហើយឧទាហរណ៍នៃកិច្ចព្រៀមនេះ គឺសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( អាស៊ាន) ។ រីឯ អង្គការពាណិជ្ជកម្មពិភពលោក គឺជាឧទាហរណ៍មួយនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី ហើយប្រព័ន្ធនេះមានភាពប្រសើរជាងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ពីព្រោះច្បាប់នេះមានតម្លាភាព សមភាពជាង និងគ្រប់សមាជិកត្រូវអនុវត្តតាម ។ ខណៈដែលកិច្ចចរចារពាណិជ្ជកម្មទ្វេភា គឺមានការពេញចិត្តជាខ្លាំងចំពោះប្រទេសដែលមានប្រៀបជាងប្រទេសជាដៃគូ ។

## ៧. តើ GATT-WTO បង្កើតឡើងយ៉ាងដូចម្តេច?

មុនពេលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក (WTO) គេបានបង្កើតកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និង ពាណិជ្ជកម្ម (GATT) ក្នុងឆ្នាំ ១៩៤៧ នៅទីក្រុង Bretton Woods ស្របពេលជាមួយនឹងការបង្កើតធនាគារ ពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។ GATT ត្រូវបានគេបង្កើតឡើង ដើម្បីសម្រេចនូវការកាត់បន្ថយ របាំងពាណិជ្ជកម្មតាមរយៈការចរចារជាទៀងទាត់ ដែលបានប្រព្រឹត្តតាំងពីឆ្នាំ ១៩៤៨ ដល់ ១៩៩៥ ហើយការចរចារ នេះបានឈានដល់ការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ។

អង្គការពាណិជ្ជកម្មពិភពលោក ជាស្ថាប័នដឹកនាំប្រព័ន្ធពាណិជ្ជកម្មពហុភាគី ហើយត្រូវបានបង្កើតឡើងនាកិច្ចចរចារជុំទី ៨ នៅប្រទេស អ៊ុយរ៉ាហ្គាយ ដើម្បីជំនួស GATT ។ នៅក្នុងកិច្ចប្រជុំអ៊ុយរ៉ាហ្គាយនេះ គេបានពិភាក្សាទៅលើ កិច្ចព្រមព្រៀងជាច្រើនចំនួន ១៧ ដូចខាងក្រោម:

**កិច្ចព្រមព្រៀងទៅលើពាណិជ្ជកម្មទំនិញ:**

- កសិកម្ម
- វិធានការណ៍អនាម័យ និងភូតគាមអនាម័យ
- វាយនភណ្ឌ និងសំលៀកបំពាក់
- របាំងបច្ចេកទេសទៅលើពាណិជ្ជកម្ម
- វិធានការណ៍វិនិយោគលើពាណិជ្ជកម្ម (TRIMS)

- Anti-dumping
- ការវាយតម្លៃពន្ធគយ
- ការត្រួតពិនិត្យមុនបញ្ជូនទំនិញ
- ច្បាប់នៃប្រភពដើម
- ការចេញអាជ្ញាប័ណ្ណនាំចូល
- វិធានការណ៍ទៅលើការឧបត្ថម្ភធន និងការរាំង
- វិធានការណ៍ការពារ

**កិច្ចព្រមព្រៀងពាណិជ្ជកម្មដាច់ដោយឡែក**

- កិច្ចព្រមព្រៀងពាណិជ្ជកម្មលើសេវាកម្ម
- កម្មសិទ្ធបញ្ញា
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទៅលើយន្តហោះស៊ីវិល, កិច្ចព្រមព្រៀងលើការផ្តល់ការអនុញ្ញាតិរបស់រដ្ឋាភិបាល, កិច្ចព្រមព្រៀងលើផលិតផលធ្វើពីទឹកដោះគោជាអន្តរជាតិ, កិច្ចព្រមព្រៀងទៅលើសាច់ពីសត្វនានាគោ ជាអន្តរជាតិ

**យន្តការ**

- ការយោគយល់ទៅលើការដោះស្រាយជម្លោះ
- យន្តការពិនិត្យឡើងវិញលើគោលនយោបាយពាណិជ្ជកម្ម

### ៨. តើអ្វីទៅជាលក្ខណៈមូលដ្ឋានរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក?

គោលការណ៍មូលដ្ឋាន ដែលប្រើសម្រាប់សមាជិក WTO ទាំងអស់ មានគោលការណ៍ Most Favoured Nation (MFN), national treatment និង single undertaking ។ គោលការណ៍ MFN គឺថាគ្រប់ប្រទេសជាសមាជិកគួរប្រើច្បាប់ពាណិជ្ជកម្មដូចៗគ្នាទៅលើសមាជិកទាំងអស់នៃ WTO មានន័យថា គោលនយោបាយពាណិជ្ជកម្មដែលប្រទេសកម្ពុជាប្រើជាមួយប្រទេសចិន គួរតែប្រើជាមួយប្រទេសជាសមាជិកដទៃទៀតនៃ WTO ។ គោលការណ៍ MFN ត្រូវបានចាត់ទុកថា ជាគន្លឹះនៅក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្មស្តង់ដារ ជាសកលនៅក្នុងការធ្វើពាណិជ្ជកម្មពហុភាគី ។ ចំណែកឯគោលការណ៍ national treatment ធ្វើឱ្យប្រាកដថា គោលនយោបាយក្នុងស្រុករបស់សមាជិកត្រូវស្របជាមួយគោលនយោបាយប្រើជាមួយដៃគូពាណិជ្ជកម្មដែលជា សមាជិក WTO ។ ឧទាហរណ៍: ប្រសិនបើ ប្រទេសកម្ពុជាហាមឃាត់ ការនាំចូលផលិតផលដែលមានសារធាតុពុលខ្ពស់ នោះរដ្ឋាភិបាលក៏ត្រូវហាមឃាត់ផលិតករក្នុងស្រុកក្នុងការផលិតផលិតផលនោះដែរ ។ រីឯ គោលការណ៍ single undertaking

មានន័យថា ប្រទេសនានាមិនអាចរើសយកការមិនទទួលយកកិច្ចព្រមព្រៀងមួយ ដែលយល់ថាគ្មាន ប្រយោជន៍ដល់ប្រទេសខ្លួនទេ។ ជាមួយគោលការណ៍single undertaking សមាជិកទាំងអស់ តាំងចិត្តអនុវត្តតាមកិច្ចព្រមព្រៀងទាំងអស់ ដែលបានឯកភាពដោយ WTO ។

WTO ទទួលស្គាល់ថា រដ្ឋាភិបាលនីមួយៗមានកំរិតអភិវឌ្ឍន៍ និងធនធានមានស្រាប់ខុសៗគ្នា ដូច្នេះ WTO ក៏យល់ព្រមលើគោលនយោបាយ Special and Differential Treatment ។ នេះមានន័យថា ប្រទេសជឿនលឿន ទទួលរងការកាត់ពន្ធគយច្រើន និងប្រើរយៈពេលខ្លីដើម្បីអនុវត្តការកាត់ពន្ធ រីឯប្រទេសក្រីក្រត្រូវបានផ្តល់ការ អនុគ្រោះតាមរយៈការកាត់ពន្ធគយតិច និងប្រើរយៈពេលយូរដើម្បីអនុវត្តការកាត់ពន្ធ។